UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

# ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា សូមស្វាគមន៍ សេចក្តីសំរេចរបស់សាលាដំបូងខេត្តតាកែវ ចំពោះការលើកលែងចោទអ្នកការពារសិទ្ធិមនុស្ស ក្នុងស្រុក និងអ្នកសារព័ត៌មាន

**ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាសូមស្វាគមន៍សាលក្រមសាលា ដំបូងខេត្តតាកែវ ចំពោះការលើកលែងចោទអ្នកការពារសិទ្ធិមនុស្សក្នុងស្រុកពីររូប គឺលោកជាប ជីវ និងលោកខឹមសារុម ព្រម ទាំងអ្នកយកព័ត៌មានឲ្យវិទ្យុអាស៊ីសេរី គឺលោកសុខ សេរី និងអ្នកតំណាងផ្សេងទៀតនៃសហគមន៍ខ្មែរ-ឥស្លាម គឺលោកនី សាន និងលោកសេប ស្មៀន ពីបទផ្សាយព័ត៌មានមិនពិត។ សេចក្តីសំរេចរបស់តុលាការ គឺជាជំហានដ៏មានអត្ថន័យមួយ ឆ្ពោះទៅរកការការពារសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ក្នុងការសំដែងមតិដោយសេរី និងសន្តិវិធី ពីបញ្ហាដែលពាក់ព័ន្ធនឹងប្រយោជន៍សាធារណៈ ដោយគ្មានការភ័យខ្លាចពីការប្តឹងតបវិញ។

ជាដំបូង បុគ្គល៥រូបនេះ ត្រូវបានប្តឹងចោទ បន្ទាប់ពីកិច្ចសំភាសន៍មួយជាមួយវិទ្យុអាស៊ីសេរី កាលពីខែធ្នូឆ្នាំ២០០៨ ដែលក្នុងកំឡុងពេលសំភាសន៍នោះ ពួកគេបានចោទមន្រ្តីមើលការខុសត្រូវវិហារឥស្លាម ក្នុងភូមិកំពុងយោល ខេត្តតាកែវ ពីបទពុករលួយ។ ពួកគេទាំង៥ ត្រូវបានចោទពីបទផ្សាយព័ត៌មានមិនពិត តាមបទបញ្ញត្តិព្រហ្មទណ្ឌអ៊ុនតាក់ កាលពីខែកញ្ញា ឆ្នាំ២០០៩។ បទល្មើសនេះ ទាមទារឲ្យមានធាតុផ្សំ ទាំងចេតនាទុច្ចរិត ទាំងភស្តុតាង ថា ព័ត៌មានដែលបានផ្សព្វផ្សាយ នឹង ″រំខាន ឬដូចជារំខានដល់សន្តិភាពសាធារណៈ″ ។ វាប្រាកដណាស់ថា នៅក្នុងរឿងក្តីនេះ កិច្ចសំភាសន៍ ធ្វើឡើងដោយគ្រាន់ តែមានការអធិប្បាយខ្លះដែលអាចចាត់ទុកយ៉ាងច្បាស់ថា វាគឺជាការពិតដែលត្រូវបានគិតថាជា″ប្រយោជន៍សាធារណៈ″។ ការអធិប្បាយដោយជនត្រូវចោទ គឺស្របតាមសិទ្ធិមានសេរីភាពនៃការបញ្ចេញមតិដែលធានាការពារដោយរដ្ឋធម្មនុញ្ញកម្ពុជា។

ក្នុងការធ្វើសេចក្តីសំរេចលើកលែងចោទពីបទផ្សាយព័ត៌មានមិនពិត សាលាដំបូងខេត្តតាកែវ បានគូសបញ្ជាក់យ៉ាងច្បាស់ថា ជនត្រូវចោទពុំមានចេតនាទុច្ចរិត ដែលជាធាតុផ្សំចាំបាច់មួយនៃបទផ្សាយព័ត៌មានមិនពិតនោះទេ។ ការិយាល័យសូមលើកទឹកចិត្តដល់ចៅក្រមដទៃទៀត ឲ្យយកចិត្តទុកដាក់ពីការសំរេចក្តីនេះ នៅក្នុងការបកស្រាយ និងការអនុវត្តន៍ច្បាប់របស់ខ្លួន ដើម្បីដាក់កំហិតដល់សេរីភាព នៃការសំដែងមតិស្របតាមកាតព្វកិច្ចសន្ធិសញ្ញាសិទ្ធិមនុស្សរបស់កម្ពុជា។ ទាំងអស់នេះ នឹងរិតតែសំខាន់ទៀត នៅពេលដែលក្រមព្រហ្មទណ្ឌទាំងមូលចូលជាធរមាននៅដំណាច់ឆ្នាំ២០១០នេះ ដោយសារថា មានបទបញ្ញត្តិមួយចំនួននៃក្រមព្រហ្មទណ្ឌ អាចមានសក្តានុពលដាក់កំហិតដល់សេរីភាពនៃការបញ្ចេញមតិ។

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org